# មូលដ្ឋានគ្រឹះនៃបណ្ដឹងរដ្ឋប្បវេណី

វិទ្យាស្ថានស្រាវជ្រាវច្បាប់ទូទៅ
នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
សាស្ត្រាចារ្យ Kai Yuji

# ដំណាក់កាលបីនៃបណ្ដឹងរដ្ឋប្បវេណី

**ដំណាក់កាលនៃការទាមទារ**

ការទាមទាររបស់ដើមចោទ → ការឆ្លើយតបរបស់ចុងចម្លើយ

"ត្រូវបង់១ម៉ឺនដុល្លារ"

- ករណីទទួលស្គាល់→ទទួលស្គាល់
- ករណីវិវាទ→ធ្វើការអះអាង

**ដំណាក់កាលនៃការអះអាង**

ការអះអាងរបស់ដើមចោទ → ការទទួលស្គាល់ ឬមិនទទួលស្គាល់របស់ចុងចម្លើយ

- អង្គហេតុដែលជាមូលហេតុនៃការទាមទារ A
- អង្គហេតុដែលជាមូលហេតុនៃការទាមទារ B

- ទទួលស្គាល់ A →សារភាព
- បដិសេធ B →បញ្ជាក់ភស្តុតាង

**ដំណាក់កាលនៃការបញ្ជាក់ភស្តុតាង**

បញ្ជាក់ភស្តុតាង

ភស្តុតាង→អង្គហេតុ B

បញ្ជាក់ភស្តុតាងតប

## 1. ដំណាក់កាលនៃការទាមទារ

ការទាមទាររបស់ដើមចោទ → ការឆ្លើយតបរបស់ចុងចម្លើយ

**ការទាមទាររបស់ដើមចោទ**

- គោលគំនិតនៃការទាមទារ :
  - “ចុងចម្លើយត្រូវបង់ប្រាក់១ម៉ឺនដុល្លារទៅឱ្យដើមចោទ”
- ការបោះបង់នូវការទាមទារ (មាត្រា221)
  - បញ្ចប់បណ្តឹង
  - អានុភាពដូចគ្នានឹងសាលក្រម (មាត្រា222)

**ការឆ្លើយតបរបស់ចុងចម្លើយ**

- វិវាទ
  - ទាមទារឱ្យច្រានចោលនូវការទាមទារ
- ទទួលស្គាល់នូវការទាមទារ(មាត្រា221)
  - បញ្ចប់បណ្តឹង
  - អានុភាពដូចគ្នានឹងសាលក្រម (មាត្រា222)

## 1. ដំណាក់កាលនៃការទាមទារ

ការទាមទាររបស់ដើមចោទ

- Ex) ឱ្យសងប្រាក់កម្ចី១ម៉ឺនដុល្លារ។
- គោលគំនិតនៃការទាមទារ :
  - “ចុងចម្លើយត្រូវបង់១ម៉ឺនដុល្លារចំពោះដើមចោទ”
  - នេះគឺជាការបង្ហាញអំពីសាលក្រមដែលទាមទារ

# 1. ដំណាក់កាលនៃការទាមទារ

ការទាមទាររបស់ដើមចោទ

- កម្មវត្ថុនៃបណ្តឹង : សិទ្ធិដែលជាមូលដ្ឋាននៃការទាមទារ
  - “សិទ្ធិទាមទារឱ្យសងប្រាក់កម្ចីដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ”
- កម្មវត្ថុនៃការជំនុំជម្រះត្រូវបានកំណត់។
  - បញ្ជាក់ឱ្យច្បាស់លាស់ថា តើតុលាការត្រូវធ្វើការជំនុំជម្រះអំពីអ្វី។
  - បញ្ជាក់ឱ្យច្បាស់លាស់ថា តើចុងចម្លើយត្រូវការពារចំពោះអ្វី។

# 1. ដំណាក់កាលនៃការទាមទារ

ការទាមទាររបស់ដើមចោទ

- កម្មវត្ថុនៃបណ្តឹង ត្រូវបានកំណត់តាមរយៈគោលគំនិតនៃការទាមទារ និង មូលហេតុនៃការទាមទារដែលមានសរសេរនៅក្នុងពាក្យបណ្តឹង។
- នៅជប៉ុន  គេគិតថា នៅវគ្គចុងក្រោយនៃពាក្យបណ្តឹងត្រូវបង្ហាញឱ្យច្បាស់លាស់អំពីកម្មវត្ថុនៃបណ្តឹងតាមរយៈការសរសេរថា “ហេតុនេះហើយ ..........”។
  - “ហេតុនេះហើយ ចុងចម្លើយត្រូវបង់ប្រាក់១ម៉ឺនដុល្លារចំពោះដើមចោទ ដោយផ្អែកលើសិទ្ធិទាមទារឱ្យសងប្រាក់កម្ចី ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ”។

# 1. ដំណាក់កាលនៃការទាមទារ

ការទាមទាររបស់ដើមចោទ

- ដើម្បីប្តូរកម្មវត្ថុនៃបណ្តឹង ចាំបាច់ត្រូវប្តូរបណ្តឹង (មាត្រា84)
- អាជ្ញាអស់ជំនុំនៃសាលក្រម នឹងកើតមានឡើងចំពោះអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិដែលជាកម្មវត្ថុនៃបណ្តឹង (មាត្រា194)

# 1. ដំណាក់កាលនៃការទាមទារ

ការទាមទាររបស់ដើមចោទ

- វិសាលភាពនៃការជំនុំជម្រះ ត្រូវបានកំរិតដោយខ្លឹមសារក្នុងពាក្យបណ្តឹងដែលកំណត់ដោយដើមចោទ។

  - មាត្រា182 (ចំណុចដែលត្រូវវិនិច្ឆ័យដោយសាលក្រម) 2 តុលាការមិនអាចចេញសាលក្រមចំពោះចំណុចណាដែលភាគីមិនបានសុំឡើយ។

# ដំណាក់កាលបីនៃបណ្ដឹងរដ្ឋប្បវេណី

**ដំណាក់កាលនៃការទាមទារ**

- ការទាមទាររបស់ដើមចោទ → ការឆ្លើយតបរបស់ចុងចម្លើយ
- "ត្រូវបង់១ម៉ឺនដុល្លារ"
- ·ករណីទទួលស្គាល់→ទទួលស្គាល់
- ·ករណីវិវាទ→ធ្វើការអះអាង

**ដំណាក់កាលនៃការអះអាង**

- ការអះអាងរបស់ដើមចោទ → ការទទួលស្គាល់ ឬមិនទទួលស្គាល់របស់ចុងចម្លើយ
- ·អង្គហេតុដែលជាមូលហេតុនៃការទាមទារ A
- ·អង្គហេតុដែលជាមូលហេតុនៃការទាមទារ B
- ·ទទួលស្គាល់ A→សារភាព
- ·បដិសេធ B→បញ្ជាក់ភស្តុតាង

**ដំណាក់កាលនៃការបញ្ជាក់ភស្តុតាង**

- បញ្ជាក់ភស្តុតាង
- ភស្តុតាង→អង្គហេតុ B
- បញ្ជាក់ភស្តុតាងតប

# 2. ដំណាក់កាលនៃការអះអាង

ការអះអាងរបស់ដើមចោទ → ការទទួលស្គាល់ ឬមិនទទួលស្គាល់របស់ចុងចម្លើយ

◦មូលហេតុនៃការទាមទារ :

A) បង្កើតកិច្ចសន្យា
B) ការប្រគល់ប្រាក់តាមកិច្ចសន្យា
C) កាលកំណត់សងបានមកដល់

※ទោះជាខ្វះអង្គហេតុណាមួយក៏ដោយ ក៏មិនអាចទទួលស្គាល់នូវការទាមទារដែរ។

◦ការទទួលស្គាល់ឬមិនទទួលស្គាល់ :

A) ទទួលស្គាល់(សារភាព)
B) បដិសេធ
   ➢ ដើមចោទជាអ្នកធ្វើការបញ្ជាក់ភស្តុតាង
C) អង្គហេតុជាក់ស្ដែង

# 2. ដំណាក់កាលនៃការអះអាង

**ការអះអាងរបស់ដើមចោទ**

- Ex) ចូរសងប្រាក់កម្ចី១ម៉ឺនដុល្លារ

មាត្រា578 (និយមន័យនៃការខ្ចីបរិភោគ)

ការខ្ចីបរិភោគ សំដៅទៅលើកិច្ចសន្យាមួយ ដែលភាគីម្ខាង ហៅថាអ្នកឱ្យខ្ចី មានករណីយកិច្ចប្រគល់ការប្រើប្រាស់ដោយសេរី នូវប្រាក់ស្បៀងអាហារ ស្រូវ ឬ វត្ថុជំនួសផ្សេងទៀត ក្នុងអំឡុងពេលដែលមានកំណត់ឱ្យទៅភាគីម្ខាងទៀត ហៅថាអ្នកខ្ចី ហើយនៅក្រោយពេលដែលអំឡុងពេលនោះបានកន្លងផុត អ្នកខ្ចីមានករណីយកិច្ចសងទៅឱ្យអ្នកឱ្យខ្ចីវិញ នូវវត្ថុដែលមានប្រភេទ គុណភាព និង ចំនួន ស្មើគ្នានឹងវត្ថុដែលបានទទួលពីអ្នកឱ្យខ្ចីនោះ ។

មាត្រា591 (ករណីយកិច្ចត្រូវសងប្រាក់ដើម និង បង់ការប្រាក់របស់អ្នកខ្ចី)

(1) អ្នកខ្ចី មានករណីយកិច្ចត្រូវសងទៅអ្នកឱ្យខ្ចី នូវវត្ថុដែលមានប្រភេទ គុណភាព និង ចំនួន ស្មើគ្នានឹងវត្ថុដែលបានទទួលការប្រគល់ នៅថ្ងៃដែលត្រូវសង ។

# 2. ដំណាក់កាលនៃការអះអាង

**ការអះអាងរបស់ដើមចោទ**

- មូលហេតុនៃការទាមទារ គឺជា :
  - អង្គហេតុចាំបាច់យ៉ាងតិចបំផុត ដើម្បីឱ្យសិទ្ធិដែលជាកម្មវត្ថុនៃបណ្តឹង កើតមានឡើង
- អង្គហេតុ ភាគីធ្វើការអះអាង

↓

- ច្បាប់ តុលាការអនុវត្តច្បាប់

↓

- អានុភាព ការកើតឡើងនៃសិទ្ធិ

## 2. ដំណាក់កាលនៃការអះអាង

- អង្គហេតុ（មូលហេតុនៃការទាមទារ）：
  - A)ការបង្កើតកិច្ចសន្យា
  - B)ការប្រគល់ប្រាក់តាមកិច្ចសន្យា
  - C)កាលកំណត់សងបានមកដល់
- ច្បាប់
  - មាត្រា578（និយមន័យនៃការខ្ចីបរិភោគ）
    ការខ្ចីបរិភោគ សំដៅ .......
  - មាត្រា591（ករណីយកិច្ចត្រូវសងប្រាក់ដើម និង បង់ការប្រាក់របស់អ្នកខ្ចី）
    (1) អ្នកខ្ចី មានករណីយកិច្ចត្រូវសងទៅអ្នកឱ្យខ្ចី នូវវត្ថុដែលមានប្រភេទ គុណភាព និង ចំនួនស្មើគ្នានឹងវត្ថុដែលបានទទួលការប្រគល់ នៅថ្ងៃដែលត្រូវសង ។
- អានុភាព：សិទ្ធិទាមទារឱ្យសងប្រាក់កម្ចី

## 2. ដំណាក់កាលនៃការអះអាង

ការអះអាងរបស់ដើមចោទ

- មូលហេតុនៃការទាមទារ：
  - A) ការបង្កើតកិច្ចសន្យា
  - B) ការប្រគល់ប្រាក់តាមកិច្ចសន្យា
  - C) កាលកំណត់សងបានមកដល់

  - មាត្រា95（អង្គហេតុដែលអាចយកមកធ្វើជាមូលដ្ឋាននៃសាលក្រម）

  តុលាការមិនអាចយកអង្គហេតុណា ដែលភាគីណាមួយមិនបានអះអាង មកធ្វើជាមូលដ្ឋាននៃសាលក្រមបានឡើយ ។

※បើសិនជាដើមចោទមិនបានអះអាងនូវអង្គហេតុ A, B, C ទេ មិនត្រូវយកអង្គហេតុនោះមកធ្វើការវិនិច្ឆ័យទេ ហើយត្រូវច្រានចោលនូវការទាមទារ។

→ការទទួលខុសត្រូវក្នុងការអះអាង

## 2. ដំណាក់កាលនៃការអះអាង

ការទទួលស្គាល់ ឬ មិនទទួលស្គាល់របស់ចុងចម្លើយ

- ការទទួលស្គាល់ ឬមិនទទួលស្គាល់របស់ចុងចម្លើយ :
  A) បង្កើតកិច្ចសន្យា → ទទួលស្គាល់
  B) ប្រគល់ប្រាក់តាមកិច្ចសន្យា → មិនទទួលស្គាល់
  C) កាលកំណត់បង់បានមកដល់ → អង្គហេតុជាក់ស្តែង

## 2. ដំណាក់កាលនៃការអះអាង

ការទទួលស្គាល់ ឬ មិនទទួលស្គាល់របស់ចុងចម្លើយ

※ស្តីពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ ចុងចម្លើយត្រូវឆ្លើយ "ទទួលស្គាល់" ឬ "មិនទទួលស្គាល់" ឬ "មិនដឹង" លើកលែងតែចំពោះអង្គហេតុជាក់ស្តែង។

※ក្នុងករណីដែលមិនឆ្លើយអ្វីទាំងអស់ ត្រូវចាត់ទុកថា បានសារភាព។

មាត្រា ៩៦ ការចាត់ទុកថាបានសារភាព

១- ក្នុងករណីដែលភាគីមិនបានបង្ហាញច្បាស់លាស់ នូវឆន្ទៈតវ៉ាអំពីអង្គហេតុដែលភាគីម្ខាងទៀតបានអះអាង នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង ការទាញហេតុផលដោយផ្ទាល់មាត់ទេ ភាគីនោះត្រូវបានចាត់ទុកថាបាន សារភាពអំពីអង្គហេតុនោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលតុលាការគិតពិចារណាអំពីដំណើរការ និង ខ្លឹមសារនៃរឿងក្តី ហើយយល់ឃើញថា ភាគីនោះបានតវ៉ាអំពីអង្គហេតុ ។

២- ក្នុងករណីដែលភាគីធ្វើសេចក្តីថ្លែងការណ៍ថា ខ្លួនមិនដឹងអំពីអង្គហេតុដែលភាគីម្ខាងទៀតបានអះអាង ភាគីនោះត្រូវបានសន្មតថា បានតវ៉ាអំពីអង្គហេតុនោះ ។

## 2. ដំណាក់កាលនៃការអះអាង

ការទទួលស្គាល់ ឬ មិនទទួលស្គាល់របស់ចុងចម្លើយ

- ការទទួលស្គាល់ ឬមិនទទួលស្គាល់របស់ចុងចម្លើយ :
  - A) ទទួលស្គាល់(សារភាព)
  - C) អង្គហេតុជាក់ស្តែង

មាត្រា123 （គោលការណ៍សម្រេចសេចក្តីដោយភស្តុតាង）
2　អង្គហេតុដែលភាគីបានសារភាពនៅចំពោះមុខតុលាការ និង អង្គហេតុដែលតុលាការយល់ឃើញថា មានភាពជាក់ស្តែង តុលាការពុំចាំបាច់ទទួលស្គាល់អង្គហេតុនោះដោយផ្អែកលើភស្តុតាងទេ ។

※តុលាការមិនអាចធ្វើការទទួលស្គាល់នូវអង្គហេតុផ្សេងពីការសារភាពបានទេ  ដូច្នេះ មិនចាំបាច់ធ្វើការបញ្ជាក់ដោយភស្តុតាងឡើយ។

## 2. ដំណាក់កាលនៃការអះអាង

ការទទួលស្គាល់ ឬ មិនទទួលស្គាល់របស់ចុងចម្លើយ

- ការសារភាពតាមផ្លូវតុលាការ : គឺជាការធ្វើសេចក្តីថ្លែងការទទួលស្គាល់នូវអង្គហេតុដែលអះអាងដោយភាគីម្ខាងទៀត ហើយដែលធ្វើឱ្យបាត់បង់ផលប្រយោជន៍របស់ខ្លួន
  - a. មិនចាំបាច់បញ្ជាក់ភស្តុតាង(មាត្រា123 កថាខ័ណ្ឌទី2)
  - b. ចងតុលាការ
  - c. ការដកការសារភាព ត្រូវបានកម្រិត(មាត្រា123 កថាខ័ណ្ឌទី3)

មាត្រា123 （គោលការណ៍សម្រេចសេចក្តីដោយភស្តុតាង）
2　អង្គហេតុដែលភាគីបានសារភាពនៅចំពោះមុខតុលាការ និង អង្គហេតុដែលតុលាការយល់ឃើញថា មានភាពជាក់ស្តែង តុលាការពុំចាំបាច់ទទួលស្គាល់អង្គហេតុនោះដោយផ្អែកលើភស្តុតាងទេ ។
3 ភាគីអាចដកសេចក្តីសារភាពបាន ក្នុងករណីដូចខាងក្រោមនេះ ៖
ក-　ភាគីម្ខាងទៀតពុំតវ៉ា ។
ខ-　ការសារភាពនោះ ផ្ទុយនឹងការពិត ដោយភាន់ច្រឡំ ។
គ-　ការសារភាពនេះបណ្តាលមកពីសកម្មភាពបទល្មើសរបស់អ្នកដទៃ ។

## 2. ដំណាក់កាលនៃការអះអាង

ការទទួលស្គាល់ ឬមិនទទួលស្គាល់របស់ចុងចម្លើយ

- ការទទួលស្គាល់ ឬមិនទទួលស្គាល់របស់ចុងចម្លើយ :

  B) មិនទទួលស្គាល់

※ស្តីពីអង្គហេតុដែលមានវិវាទ (ចំណុចវិវាទ) តុលាការត្រូវធ្វើការវិនិច្ឆ័យថា ទទួលស្គាល់ ឬមិនទទួលស្គាល់នូវអង្គហេតុនោះ។

## ដំណាក់កាលបីនៃបណ្តឹងរដ្ឋប្បវេណី

| | | |
|---|---|---|
| ដំណាក់កាលនៃការទាមទារ | ការទាមទាររបស់ដើមចោទ → <br>“ត្រូវបង់១ម៉ឺនដុល្លារ” | ការឆ្លើយតបរបស់ចុងចម្លើយ<br>·ករណីទទួលស្គាល់→ទទួលស្គាល់<br>·ករណីវិវាទ→ធ្វើការអះអាង |
| ដំណាក់កាលនៃការអះអាង | ការអះអាងរបស់ដើមចោទ → <br>·អង្គហេតុដែលជាមូលហេតុនៃការទាមទារ A<br>·អង្គហេតុដែលជាមូលហេតុនៃការទាមទារ B | ការទទួលស្គាល់ ឬមិនទទួលស្គាល់របស់ចុងចម្លើយ<br>·ទទួលស្គាល់ A→សារភាព<br>·បដិសេធ B→បញ្ជាក់ភស្តុតាង |
| ដំណាក់កាលនៃការបញ្ជាក់ភស្តុតាង | បញ្ជាក់ភស្តុតាង<br>ភស្តុតាង→អង្គហេតុ B | បញ្ជាក់ភស្តុតាងតប |

## 3. ដំណាក់កាលនៃការបញ្ជាក់ភស្តុតាង

- ចំណោទវិវាទ : ការប្រគល់ប្រាក់តាមកិច្ចសន្យា
- ស្តីពីអង្គហេតុដែលមានវិវាទ តុលាការត្រូវធ្វើការវិនិច្ឆ័យដោយផ្អែកលើភស្តុតាង។

មាត្រា123 (គោលការណ៍សម្រេចសេចក្តីដោយភស្តុតាង)

1 តុលាការត្រូវទទួលស្គាល់អង្គហេតុដោយផ្អែកលើភស្តុតាងជាមូលដ្ឋាន ។

## 3. ដំណាក់កាលនៃការបញ្ជាក់ភស្តុតាង

- គោលការណ៍នៃជំនឿទុកចិត្តដោយសេរី : ចៅក្រមអាចធ្វើការទទួលស្គាល់នូវអង្គហេតុ តាមការវាយតម្លៃដោយសេរីរបស់ខ្លួនបាន។
  - មាត្រា184 (គោលការណ៍ជំនឿទុកចិត្តដោយសេរី)
  - ក្នុងការចេញសាលក្រម តុលាការត្រូវវិនិច្ឆ័យទទួលស្គាល់ ឬ មិនទទួលស្គាល់ថា ការអះអាងអំពីអង្គហេតុ មានពិត ឬមិនមាន ដោយគិតពិចារណាយ៉ាងហ្មត់ចត់នូវលទ្ធផលនៃការពិនិត្យភស្តុតាង និង ដំណើរការនិងខ្លឹមសារនៃការទាញហេតុផលដោយផ្ទាល់មាត់ តាមជំនឿទុកចិត្តដោយសេរីរបស់ខ្លួន ។
- ធ្វើការវិនិច្ឆ័យតាមរូបមន្តនៃបទពិសោធន៍ (ចំណេះដឹង ឬ រូបមន្តបានមកពីការពិសោធន៍)
  - Ex)តាមធម្មតា បើសិនជាមិនបានទទួលប្រាក់ទេ គេមិនដែលចេញវិក័យប័ត្រឱ្យទេ។

## 3. ដំណាក់កាលនៃការបញ្ជាក់ភស្តុតាង

- ជាគោលការណ៍ ភស្តុតាងត្រូវដាក់ដោយភាគី
- បើសិនជាមានការចាំបាច់ តុលាការអាចធ្វើការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិបាន។
  - មាត្រា124 (ការពិនិត្យភស្តុតាង)
  - 1. ការពិនិត្យភស្តុតាង ត្រូវធ្វើឡើងតាមការស្នើសុំឱ្យពិនិត្យរបស់ភាគី ។
  - 2. ប្រសិនបើតុលាការពុំអាចសម្រេចថា ត្រូវទទួលស្គាល់ ឬ មិនទទួលស្គាល់នូវការអះអាងអំពីអង្គហេតុ ដោយភស្តុតាងដែលគូភាគីបានស្នើសុំឱ្យពិនិត្យ ឬ បើយល់ឃើញថា មានការចាំបាច់ផ្សេងទៀត នោះតុលាការអាចធ្វើការពិនិត្យភស្តុតាង ដោយឆន្ទានុសិទ្ធិបាន ។

## 3. ដំណាក់កាលនៃការបញ្ជាក់ភស្តុតាង

- ចំណុចវិវាទ : ការប្រគល់ប្រាក់តាមកិច្ចសន្យា
- ក្នុងករណីដែលមិនអាចទទួលស្គាល់នូវអង្គហេតុនេះដោយភស្តុតាងបានទេ មិនអាចទទួលស្គាល់នូវការទាមទាររបស់ដើមចោទបានឡើយ។

  →ការទទួលខុសត្រូវក្នុងការពិនិត្យភស្តុតាង

## 3. ដំណាក់កាលនៃការបញ្ជាក់ភស្តុតាង

- ភស្តុតាង
  - A)មិនចាំបាច់ (មានការសារភាព)
  - B)វិក័យប័ត្រ ជាដើម
  - C)មិនចាំបាច់ (អង្គហេតុជាក់ស្តែង)
- រូបមន្តនៃបទពិសោធន៍
  - B) តាមធម្មតា បើសិនជាមិនបានទទួលប្រាក់ទេ គេមិនដែលចេញវិក័យប័ត្រឱ្យទេ។
- អង្គហេតុ (មូលហេតុនៃការទាមទារ)
  - A)ការបង្កើតកិច្ចសន្យា
  - B)ការប្រគល់ប្រាក់តាមកិច្ចសន្យា
  - C)កាលកំណត់សងបានមកដល់

## 3. ដំណាក់កាលនៃការបញ្ជាក់ភស្តុតាង

- ភស្តុតាង
  - A)មិនចាំបាច់ (មានការសារភាព)
  - B)វិក័យប័ត្រ ជាដើម
  - C)មិនចាំបាច់ (អង្គហេតុជាក់ស្តែង)
- រូបមន្តនៃបទពិសោធន៍
  - B) បើសិនជាមិនបានទទួលប្រាក់ទេ គេមិនដែលចេញវិក័យប័ត្រឱ្យទេ។
- អង្គហេតុ (មូលហេតុនៃការទាមទារ)
  - A)ការបង្កើតកិច្ចសន្យា
  - B)ការប្រគល់ប្រាក់តាមកិច្ចសន្យា
  - C)កាលកំណត់សងបានមកដល់
- ច្បាប់
  - ក្រមរដ្ឋប្បវេណី មាត្រា578, មាត្រា591
- អានុភាព : សិទ្ធិទាមទារឱ្យសងប្រាក់កម្ចី

# ដំណាក់កាលបីនៃបណ្ដឹងរដ្ឋប្បវេណី




# ដំណាក់កាលបីនៃបណ្ដឹងរដ្ឋប្បវេណី

